

ខុមហ្វ្រែល COMFREL

# របាយការណ៍ឆ្នាំ២០១២

## របាយការណ៍សង្ខេប
## ការវាយតម្លៃលើការឆ្លើយតបរបស់តំណាងគណបក្សនយោបាយ
## នៅមូលដ្ឋាន/ក្រុមប្រឹក្សាឃុំចំពោះតម្រូវការអាទិភាពរបស់អ្នកភូមិ
## នៅឃុំដាច់ស្រយាល និងឃុំជនជាតិដើមភាគតិច



ផលិតដោយ: ផ្នែកបណ្តាញខុមហ្វ្រែល ខែមករា ឆ្នាំ២០១៣

## មាតិកា

សេចក្តីផ្តើម ........ ១

វិធីសាស្ត្រ ........ ១

អ្នកចូលរួមវាយតម្លៃ ........ ៣

លទ្ធផលវាយតម្លៃ ........ ៤

ឧបសម្ព័ន្ធ ........ ២០

## ១.សេចក្តីផ្តើម

ដោយបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីសហភាពអឺរ៉ុប គណៈកម្មាធិការដើម្បីការបោះ ឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានរៀបចំសិក្ខាសាលា ស្តីពីការកំណត់តម្រូវការជាអាទិភាពនៅឃុំដាច់ស្រយាលចំនួន១០០ឃុំ នៅ១៦ខេត្ត ក្នុងឆ្នាំ ២០១១-២០១២ ។

គោលបំណងនៃសិក្ខាសាលាគឺដើម្បីបង្កើនការយល់ដឹងអំពីសិទ្ធិ តួនាទី និងកាតព្វកិច្ច របស់ម្ចាស់ឆ្នោត ក្នុងការស្វែងយល់ពីតម្រូវ ការជាអាទិភាពក្នុងការអភិវឌ្ឍន៍មូលដ្ឋាន។ ផ្តល់ឱកាសឲ្យម្ចាស់ឆ្នោតបានចូលរួមពិភាក្សា ដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំរបស់ខ្លួន ហើយលទ្ធផលនៃសិក្ខសាលា ត្រូវបានមន្ត្រីជាប់ឆ្នោត ឬគណបក្សនយោបាយ យកធ្វើជាផែន ការអភិវឌ្ឍន៍ ជារបៀបវារៈ ឬជាកម្មវិធីនយោបាយសម្រាប់ ឃោសនាបោះ ឆ្នោតនាពេលខាងមុខ។

ក្រោយសិក្ខាសាលាស្តីពីការកំណត់អាទិភាពទាំង៥តាមឃុំនីមួយៗ គណៈកម្មាធិការខុមហ្វ្រែល បានធ្វើការវាយតម្លៃអំពីការបំពេញការងារ និងការឆ្លើយតបរបស់មន្ត្រីជាប់ឆ្នោត តំណាងគណបក្សនយោបាយ ជាពិសេសវាយតម្លៃលើតម្រូវអាទិភាព១ ដែលប្រជាពលរដ្ឋបានដាក់ចេញកំឡុងពេលធ្វើសិក្ខាសាលាតាមបណ្តាឃុំរបស់ខ្លួនកន្លងមក។

ការវាយតម្លៃនេះ ត្រូវបានរៀបចំឡើង ជាសកម្មភាពបន្ត ដើម្បីឱ្យប្រជាពលរដ្ឋចូលរួមតាមដានត្រួតពិនិត្យ និងវាយតម្លៃពីលទ្ធផលការងាររបស់ មន្ត្រីជាប់ឆ្នោត ជាពិសេសតម្រូវការអាទិភាពដែលប្រជាពលរដ្ឋបានលើកក្នុងសិក្ខាសាលាស្តីពីការកំណត់តម្រូវការអាទិភាពនៅឃុំដាច់ស្រយាល និងឃុំជនជាតិដើមភាគតិច។ ម្យ៉ាងវិញទៀតខុមហ្វ្រែល និងផ្សព្វផ្សាយ និងផ្តល់របាយការណ៍ស្តីពីការរីកចំរើនការអនុវត្ត និងការឆ្លើយតបរបស់មន្ត្រីជាប់ឆ្នោតលើតម្រូវការអាទិភាពដល់គណបក្សនយោបាយ សង្គមស៊ីវិល និងភាគីពាក់ព័ន្ធ។

## ២. វិធីសាស្រ្តវាយតម្លៃ

ប័ណ្ណពិន្ទុប្រជាពលរដ្ឋ (citizen's score card)ជាវិធីសាស្រ្តដែលត្រូវបានប្រើប្រាស់ក្នុងការវាយតម្លៃលើការអនុវត្តន៍ការ បំពេញការងារ ការឆ្លើយតប និងលទ្ធផលសម្រេចបានរបស់មន្ត្រីជាប់ឆ្នោត ឬតំណាងគណបក្សនយោបាយ ជាពិសេសវាយតម្លៃក្រុមប្រឹក្សាឃុំ ក្នុងការឆ្លើយតបទៅលើតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋបានដាក់ចេញក្នុងកំឡុងពេលធ្វើសិក្ខាសាលាសម្លេងម្ចាស់ឆ្នោត ក្នុងការកំណត់តម្រូវការអាទិភាពនៅឃុំដាច់ស្រយាល និងឃុំជនជាតិដើមភាគតិចកន្លងមក។

ការផ្ញើសារជាអក្សរតាមប្រព័ន្ធទូរស័ព្ទ (SMS) ត្រូវបានប្រើប្រាស់ជាមធ្យោបាយសម្រាប់បញ្ជូនព័ត៌មាន ឬទិន្នន័យពីលទ្ធផលវាយតម្លៃតាមរយៈប័ណ្ណពិន្ទុប្រជាពលរដ្ឋដោយអ្នកស្ម័គ្រចិត្តប្រចាំឃុំនីមួយៗ។

សិក្ខាសាលាសម្លេងម្ចាស់ឆ្នោតក្នុងការកំណត់តម្រូវការអាទិភាពនៅឃុំដាច់ស្រយាល និងឃុំជនជាតិដើមភាគតិចចំនួន ១០០ ត្រូវបានរៀបចំឡើង។ នៅក្នុងសិក្ខាសាលានៃឃុំនីមួយៗ ម្ចាស់ឆ្នោតបានពិភាក្សា និងកំណត់ពីតម្រូវការអាទិភាពចំនួន៥ ដើម្បីក្រុមប្រឹក្សាឃុំ ឬតំណាងគណបក្សនយោបាយយកទៅពិចារណាដាក់ក្នុងផែនការអភិវឌ្ឍឃុំ និងកម្មវិធីនយោបាយរបស់គណបក្សសម្រាប់ការបោះឆ្នោតខាងមុខ។ ហើយជារួម តម្រូវការអាទិភាពសំខាន់ចំនួន ២១ ត្រូវបានកំណត់ និងបានរៀបចំជាកូដតាមលំដាប់លំដោយ ប្រយោជន៍ងាយស្រួលក្នុងការវាយតម្លៃ និងផ្ញើរលទ្ធផលវាយតម្លៃតាមរយៈ SMS។ ខាងក្រោមគឺជា តារាងនៃកូដតម្រូវការអាទិភាព ខ្លឹមសារតម្រូវការអាទិភាព និងចំនួនឃុំដែលបានលើកឡើងតម្រូវ ការអាទិភាពទាំងនោះ។

| កូដ អាទិភាព | តម្រូវការអាទិភាព | ចំនួនឃុំនៃ តម្រូវការអាទិភាព |
|---|---|---|
| ១ | សុំសាងសង់មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព អណ្តូងទឹក ផ្តល់ឥណទានជនបទ ពេទ្យធ្មប រថយន្តសង្គ្រោះ ម៉ូតូកង់បី(តុតុ) គ្រូពេទ្យ និងបុគ្គលិកពេទ្យ | ៥៥ |
| ២ | សាងសង់ផ្លូវ ជួសជុលផ្លូវ និងស្ពាន | ៦៦ |
| ៣ | ការស្នើសុំម៉ាស៊ីនគោយន្ត វគ្គបណ្តុះបណ្តាលកសិកម្ម ពូជស្រូវ ឧបករណ៍កសិកម្ម | ១០ |
| ៤ | សាងសង់សាលារៀន និងគ្រូបង្រៀន សាលាប្រជុំភូមិ សាងសាង់ព្រះវិហារ និងសាលាឆាន់ | ៤៣ |
| ៥ | ការបង្កើតក្រុមកែច្នៃផលិតផលផ្តៅ និងវគ្គបណ្តុះ បណ្តាលជំនាញសិប្បកម្ម | ១ |
| ៦ | តម្រូវការសាងសង់ស្ថានីយបូមទឹក សាងសង់ និងស្តារប្រឡាយទឹក ជីកស្រះ ទំនប់ទឹក និងទ្វារទឹក ស្តាព្រែក ជួសជុលទំនប់អាងទឹក អាងស្តុកទឹក | ៣៤ |
| ៧ | អប់រំសុខភាព និងអនាម័យ សាងសង់បង្គន់អនាម័យ និងចម្រោះទឹកស្អាត អណ្តូងស្នប់ | ៣៦ |

| | | |
|---|---|---|
| ៨ | តបណ្ដាញអគ្គីសនី សុំម៉ាស៊ីនភ្លើង | ១១ |
| ៩ | វគ្គបណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹមសត្វ និងពូជសត្វក្របី និង ចាក់ថ្នាំវ៉ាក់សាំងសត្វ កូនឈើ និងពេទ្យសត្វ ជីកសិកម្ម | ៨ |
| ១០ | សុំជួយដោះស្រាយទំនាស់ដីធ្លី ការផ្ដល់ដីព្រៃសហគមន៍ និងបង្កើត សហគមន៍ | ២០ |
| ១១ | សុំ បង្កើតសហគមន៍ព្រៃឈើ នេសាទ ស្នើសុំការពារព្រៃបោ្រះ | ៦ |
| ១២ | ពន្លឿនការធ្វើអត្តសញ្ញាណប័ណ្ណ ការធ្វើអត្តសញ្ញាណប័ណ្ណ ការ ទប់ស្កាត់ការយកលុយធ្វើអត្តសញ្ញាណប័ណ្ណលើសកំណត់ | ៨ |
| ១៣ | បញ្ចុះតម្លៃទំនិញ បញ្ចុះតម្លៃជីកសិកម្ម ប្រេងសាំង ម៉ាស៊ូត និងផ្ដល់ ពូជស្រូវ | ៤ |
| ១៤ | ទប់ស្កាត់ក្មេងទំនើង សន្តិសុខសណ្ដាប់ធ្នាប់ សន្តិសុខ | ៧ |
| ១៥ | ទប់ស្កាត់ការនេសាទខុសច្បាប់ ការកាត់បន្ថយឡូត៍នេសាទ ស្នើសុំ ដាក់លប និងកាប់ព្រៃល្បាស់ ការថែរក្សាធនធានធម្មជាតិ ការទប់ ស្កាត់ការបំផ្លាញ | ១០ |
| ១៦ | កសិកម្ម និងបង្កើតទីផ្សារលក់ផលិតផលកសិកម្ម | ១ |
| ១៧ | ការបង្រៀន និងវគ្គបណ្ដុះបណ្ដាលអំពើហិង្សាក្នុងគ្រួសារ និងច្បាប់ ចរាចរ ច្បាប់ភូមិបាល រក្សាប្រពៃណី | ១០ |
| ១៨ | សុំសាងសង់ឈាបនដ្ឋាន និងស្ពានីយភ្ជាស់កូនត្រី | ១ |
| ១៩ | សុំសាងសង់ប៉ុស្ដិ៍នគរបាលរដ្ឋបាល និងសាលាឃុំ | ១ |
| ២០ | ការស្នើសុំជួយសម្រួលបញ្ហាទំនប់វារីអគ្គីសនី | ១ |
| ២១ | សុំអាហារូបករណ៍ និងរកការងារ | ១ |

## ៣. អ្នកចូលរួមវាយតម្លៃ

អ្នកស្ម័គ្រចិត្តឃុំចំនួន៣នាក់ ដែលបានជ្រើសរើសក្នុងសិក្ខាសាលាកំណត់តម្រូវការ អាទិភាពតាមឃុំនីមួយៗ ជាអ្នកប្រមូលព័ត៌មានតាមរយៈការជួបសម្ភាសន៍ជាមួយអ្នកភូមិអំពីការយល់ឃើញ និងវាយតម្លៃការឆ្លើយតបរបស់មន្ត្រីជាប់ឆ្នោត ឬតំណាងគណបក្សនយោបាយមូលដ្ឋាន លើតម្រូវការជាអាទិភាព ដែលប្រជាពលរដ្ឋបានដាក់ចេញពេលសិក្ខាសាលាក្នុងឃុំរបស់ខ្លួនកន្លងមកតាមរយៈ ផ្ដល់ពិន្ទុរួចផ្ញើរសារមកកាន់ស្នាក់ការកណ្ដាលខុមហ្វ្រែល។

អ្នកចូលរួមក្នុងសិក្ខាសាលា ១៥ នាក់នៃអ្នកចូលរួមទាំងអស់តាមបណ្តាឃុំនីមួយៗ ត្រូវបានជ្រើសរើសដើម្បីសម្ភាសន៍អំពីការយល់ឃើញរបស់ពួកគេទៅលើ ចំណុចដែលត្រូវវាយ តម្លៃ គឺផ្តោតសំខាន់លើតម្រូវការអាទិភាពទាំង៥ នៃឃុំនីមួយៗ។ អ្នកដែលបានជ្រើសរើស ត្រូវបានលើកទឹកចិត្តឱ្យចូលរួមវាយតម្លៃ តាមរយៈការផ្តល់ពិន្ទុ ទៅលើចំណុច នៃតម្រូវការ អាទិភាពនីមួយៗ នៃឃុំរបស់ខ្លួនដែលសម្រេចបានតាមការយល់ឃើញរៀងៗខ្លួន ពីលេខ ១ ដល់លេខ ៥ ដែលបាន ន័យដូចខាងក្រោម៖

១= ( ០% - ២០%) មិនបានធ្វើទាល់តែសោះ ឬបានធ្វើតិចតួច

២= ( ២១% - ៤០%) បានធ្វើខ្លះ

៣= ( ៤១% - ៦០%) បានធ្វើមធ្យម ឬបានធ្វើពាក់កណ្តាល

៤= ( ៦១% - ៨០%) បានធ្វើច្រើន

៥= ( ៨១% - ១០០%) បានធ្វើស្ទើរតែទាំងស្រុង ឬបានធ្វើទាំងស្រុង

## ៤. លទ្ធផលវាយតម្លៃ

នៅចុងឆ្នាំ២០១២ ក្នុងគោលបំណងលើកកំពស់ការចូលរួមរបស់ម្ចាស់ឆ្នោត និងពង្រឹងការទទួលខុសត្រូវរបស់មន្ត្រីជាប់ឆ្នោត ជាពិសេសសម្លេងម្ចាស់ឆ្នោតនៅឃុំដាច់ស្រយាល និងជនជាតិដើមភាគតិចក្នុងការអនុវត្តន៍វិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន គណៈកម្មាធិការខុមហ្វ្រែលបានយកតម្រូវអាទិភាពដែលប្រជាពលរដ្ឋបានកំណត់ក្នុង សិក្ខាសាលាសម្លេងម្ចាស់ឆ្នោតក្នុងការកំណត់តម្រូវការអាទិភាពឆ្នាំ ២០១០-២០១២ក្នុងឆ្នាំទៅអោយពួកគេ ដើម្បីផ្តល់ពិន្ទុវាយតម្លៃលើការបំពេញ ការឆ្លើយតបរបស់មន្ត្រីជាប់ ឆ្នោតចំពោះតម្រូវការប្រជាពលរដ្ឋដែលបានលើកឡើង។ ខាងក្រោមគឺលទ្ធផលនៃវាយតម្លៃដោយប្រជាពលរដ្ឋ:

### <u>អាទិភាពកូដលេខ១</u>៖ មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព អណ្តូងទឹក ឥណទានជនបទ ពេទ្យធ្មប រថយន្តសង្គ្រោះ ម៉ូតូកង់បី(តុតុ) គ្រូពេទ្យ និងបុគ្គលិកពេទ្យ

ក្នុងចំណោមអ្នកវាយតម្លៃ ៧០៨ នាក់នៃ៥៥ឃុំដាច់ស្រយាល មាន៤១៦ នាក់ ស្មើនឹង៥៨.៧៦% យល់ឃើញថាក្រុមប្រឹក្សា ឬ តំណាងគណបក្សនយោបាយនៅមូលដ្ឋានមិនបានធ្វើទាល់តែសោះ ឬធ្វើបានតិចតួច ចំពោះ តម្រូវការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងមកដូចជា តម្រូវការអោយមាន មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព អណ្តូងទឹកស្អាត ឥណទានជនបទ ពេទ្យធ្មប រថយន្តសង្គ្រោះបន្ទាន់ ម៉ូតូកង់បី(តុតុ)សម្រាប់មណ្ឌលសុខភាព គ្រូពេទ្យ និងបុគ្គលិកពេទ្យ។ មាន១៣៧ នាក់ ស្មើនឹង

១៩.៣៥% បានវាយតម្លៃថា ក្រុមប្រឹក្សាឃុំបានធ្វើខ្លះ ចំពោះតម្រូវការទាំង នេះ ហើយមាន ១០៥ នាក់ ស្មើនឹង ១៤.៨៣% វាយតម្លៃថា ក្រុមប្រឹក្សាឃុំ ឆ្លើយតបបានមធ្យម ឬធ្វើបានពាក់ កណ្ដាលនៃតម្រូវការ របស់អ្នកភូមិដែលបាន លើកឡើង។ មាន ៤៦ នាក់ ស្មើនឹង ៦.៥០% លើកឡើង ថា ក្រុមប្រឹក្សាឃុំធ្វើបានច្រើន ឬឆ្លើយតបបានច្រើនចំពោះ តម្រូវការអាទិភាព របស់ពួកគេ និង មាន ត្រឹមតែ ៤នាក់ ស្មើនឹង ០.៥៦% បានផ្ដល់ពិន្ទុវាយតម្លៃ ខ្ពស់បំផុតគឺថាក្រុម ប្រឹក្សាឃុំបានឆ្លើយតប ឬធ្វើបានទាំងស្រុងនៅនៃតម្រូវការអាទិភាពដែលបាន លើកឡើងក្នុងសិក្ខាសាលាកន្លងមក។




## អាទិភាពកូដលេខ២៖ សុំជួយសាងសង់ផ្លូវ ជួសជុលផ្លូវ ដាក់លូ និងស្ពាន

ក្នុងចំណោមអ្នកវាយតម្លៃ ៨៥៣ នាក់នៃ៦៤ឃុំដាច់ស្រយាល មាន៣៣៧ នាក់ ស្មើនឹង ៣៩.៥០% វាយតម្លៃថាក្រុមប្រឹក្សា ឬ តំណាងគណបក្សនយោបាយនៅមូលដ្ឋានមិនបានធ្វើទាល់តែសោះ ឬធ្វើបានតិចតួច ចំពោះ តម្រូវការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងមកដូចជា សាងសង់ផ្លូវ ជួសជុលផ្លូវ និងស្ពាន និង មាន២៤៥ នាក់ ស្មើនឹង ២៨.៧% បានវាយតម្លៃថា ក្រុមប្រឹក្សាឃុំបានធ្វើខ្លះ ចំពោះតម្រូវការទាំងនេះ ហើយមាន ១៥៩ នាក់ ស្មើនឹង ១៨.៦% វាយតម្លៃថា



ក្រុមប្រឹក្សាឃុំឆ្លើយតបបានមធ្យម ឬធ្វើបានពាក់កណ្ដាលនៃតម្រូវការរបស់អ្នក ភូមិ ដែលបានលើកឡើង។ មាន ៩៩ នាក់ ស្មើនឹង ១១.៦% លើកឡើងថា ក្រុមប្រឹក្សាឃុំធ្វើបានច្រើន ឬឆ្លើយតបបានច្រើនចំពោះ តម្រូវការអាទិភាពរបស់ពួកគេ និងមានត្រឹមតែ ១៣នាក់ ស្មើនឹង ១.៥% បានផ្ដល់ពិន្ទុវាយតម្លៃថា ក្រុមប្រឹក្សាឃុំបានឆ្លើយតប ឬធ្វើបានទាំងស្រុងនៅនៃតម្រូវការ អាទិភាពដែលបានលើកឡើងក្នុង សិក្ខាសាលាកន្លងមក។

## អាទិភាពកូដលេខ៣៖ ការស្នើសុំម៉ាស៊ីនគោយន្ត វគ្គបណ្ដុះបណ្ដាលកសិកម្ម ពូជស្រូវ ឧបករណ៍ កសិកម្ម

ក្នុងចំណោមអ្នកវាយតម្លៃ ៩៩ នាក់ នៃ១០ឃុំដាច់ស្រយាល មាន៣៣ នាក់ ស្មើនឹង៣៣.៣% វាយតម្លៃថាក្រុមប្រឹក្សា ឬតំណាងគណបក្សនយោបាយនៅមូលដ្ឋានមិនបានធ្វើទាល់តែសោះ ឬធ្វើ បានតិចតួចចំពោះ តម្រូវ ការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ ការស្នើ សុំម៉ាស៊ីនគោយន្ត វគ្គ បណ្ដុះបណ្ដាលកសិកម្ម ពូជស្រូវ និងមាន់ ឧបករណ៍កសិកម្ម និងមាន២០ នាក់ ស្មើនឹង ២០.២% បានវាយតម្លៃថា ក្រុមប្រឹក្សាឃុំបានធ្វើខ្លះចំពោះតម្រូវការទាំងនេះ ហើយ មាន ២១ នាក់ ស្មើនឹង ២១.២% វាយតម្លៃថា ក្រុមប្រឹក្សាឃុំ ឆ្លើយតបបានមធ្យម ឬធ្វើបានពាក់កណ្ដាលនៃតម្រូវការរបស់ អ្នកភូមិដែលបានលើកឡើង។ មាន ២១ នាក់ ស្មើនឹង ២១.២% លើកឡើងថា ក្រុមប្រឹក្សាឃុំធ្វើ បានច្រើន ឬឆ្លើយតបបានច្រើនចំពោះ តម្រូវការអាទិភាពរបស់ពួកគេ និងមានត្រឹមតែ ៤នាក់ ស្មើនឹង ៤.០% ផ្សេងទៀត បានផ្ដល់ពិន្ទុវាយតម្លៃថា ក្រុមប្រឹក្សាឃុំបានឆ្លើយតប ឬធ្វើបានទាំង ស្រុងនៅនៃតម្រូវការអាទិភាពដែលបានលើកឡើងក្នុង សិក្ខាសាលាកន្លងមក។



**អាទិភាពកូដលេខ៤៖ សាងសង់សាលារៀន និងគ្រូបង្រៀន សាលាប្រជុំភូមិ សាងសាង់ព្រះវិហារ និងសាលាឆាន់**

ក្នុងចំណោមអ្នកវាយតម្លៃ ៥៦៩ នាក់ នៃ៤៣ឃុំដាច់ស្រយាល មាន២៧៥ នាក់ ស្មើនឹង៤៨.៣% វាយតម្លៃថាក្រុមប្រឹក្សា ឬ តំណាងគណបក្សនយោបាយនៅមូលដ្ឋានមិនបានធ្វើទាល់តែសោះ ឬធ្វើ បានតិចតួចចំពោះតម្រូវការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ សាង សង់សាលារៀន និងគ្រូបង្រៀន សាលាប្រជុំភូមិ សាងសាង់ព្រះវិហារ និងសាលាឆាន់ និងមាន១៣៦ នាក់ ស្មើនឹង ២៣.៩% បានវាយតម្លៃថា ក្រុមប្រឹក្សាឃុំបានធ្វើខ្លះ ចំពោះតម្រូវការទាំងនេះ ហើយ មាន ៧២ នាក់ ស្មើនឹង ១៣.៤% វាយតម្លៃថាក្រុមប្រឹក្សាឃុំ ឆ្លើយ តបបានមធ្យម ឬធ្វើបានពាក់ កណ្ដាលនៃតម្រូវ ការរបស់អ្នកភូមិដែលបានលើកឡើង។ មាន ៧៦ នាក់ ស្មើនឹង ៩.៧% លើក ឡើងថា ក្រុមប្រឹក្សា ឃុំធ្វើបានច្រើន ឬឆ្លើយតបបានច្រើនចំពោះ តម្រូវការអាទិភាពរបស់ពួកគេ និងមាន ២៧នាក់ ស្មើនឹង ៤.៧% ផ្សេងទៀត បានផ្ដល់ពិន្ទុវាយតម្លៃ ថា ក្រុមប្រឹក្សាឃុំបានឆ្លើយ តប ឬធ្វើបានទាំងស្រុងនៅនៃតម្រូវការអាទិភាពដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងមក។



## អាទិភាពកូដលេខ៥៖ ការបង្កើតក្រុមកែច្នៃផលិតផលផ្តៅ និងវគ្គបណ្តុះ បណ្តាលជំនាញសិប្បកម្ម




ក្នុងចំណោមអ្នកវាយតម្លៃ ៦ នាក់ នៃ១ឃុំដាច់ស្រយាល មាន៥ នាក់ ស្មើនឹង៨៣.៣% វាយតម្លៃ ថាក្រុមប្រឹក្សា ឬ តំណាងគណបក្សនយោបាយនៅមូលដ្ឋាន មិនបានធ្វើទាល់តែសោះ ឬធ្វើបានតិច តួចចំពោះ តម្រូវ ការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ ការបង្កើតក្រុម កែច្នៃផលិតផលផ្តៅ និងវគ្គបណ្តុះបណ្តាលជំនាញសិប្បកម្ម និងមានតែ១ នាក់ ស្មើនឹង ១៦.៧% បានវាយតម្លៃថា ក្រុម ប្រឹក្សាឃុំបានធ្វើខ្លះ ចំពោះតម្រូវការទាំងនេះ។

## អាទិភាពកូដលេខ៦៖ សាងសង់ស្ថានីយបូមទឹក សាងសង់ និងស្ពានប្រឡាយទឹក ជីកស្រះ ទំនប់ទឹក និងទ្វារទឹក ស្តារព្រែក ជួសជុលទំនប់អាងទឹក អាងស្តុកទឹក

ក្នុងចំណោមអ្នកវាយតម្លៃ ៤៣០ នាក់ នៃ៣៤ឃុំដាច់ស្រយាល មាន២៤៤ នាក់ ស្មើនឹង៥៦.៧% វាយតម្លៃថាក្រុមប្រឹក្សា ឬ តំណាងគណបក្សនយោបាយនៅមូលដ្ឋាន មិនបានធ្វើទាល់តែសោះ ឬធ្វើបានតិចតួចចំពោះ តម្រូវការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ តម្រូវការសាងសង់ស្ថានីយបូម



ទឹក តម្រូវការសាងសង់ និងស្ដារប្រឡាយទឹក ជីកស្រះ ទំនប់ទ្វារទឹក ស្ដាព្រែក និងអាងស្តុកទឹក និង មាន ១០៣ នាក់ ស្មើនឹង ២៤.០% បានវាយតម្លៃថា ក្រុមប្រឹក្សាឃុំបានធ្វើខ្លះ ចំពោះតម្រូវការ ទាំងនេះ ហើយមាន ៥៩ នាក់ ស្មើនឹង ១៣.៧% វាយតម្លៃថាក្រុមប្រឹក្សាឃុំ ឆ្លើយតបបានមធ្យម ឬធ្វើបានពាក់កណ្ដាលនៃតម្រូវ ការរបស់អ្នកភូមិដែលបានលើកឡើង។ មាន ១៥ នាក់ ស្មើនឹង ៣.៥% លើកឡើងថា ក្រុមប្រឹក្សា ឃុំធ្វើបានច្រើន ឬឆ្លើយតបបានច្រើនចំពោះតម្រូវការអាទិភាព របស់ពួកគេ និងមាន៩ នាក់ ស្មើនឹង ២.១% ផ្សេងទៀត បានផ្ដល់ពិន្ទុវាយតម្លៃថា ក្រុមប្រឹក្សាឃុំ បានឆ្លើយតប ឬធ្វើបានទាំង ស្រុងនៅនៃតម្រូវការអាទិភាពដែលបានលើកឡើងក្នុង សិក្ខាសាលាកន្លងមក។

## អាទិភាពកូដលេខ៧៖ អប់រំសុខភាព និងអនាម័យ សាងសង់បង្គន់អនាម័យ និងចម្រោះទឹកស្អាត អណ្ដូងស្នប់

ក្នុងចំណោមអ្នកវាយតម្លៃ ៤៧៩ នាក់ នៃ៣៦ឃុំដាច់ស្រយាល មាន២៧០ នាក់ ស្មើនឹង៥៤.៥% វាយតម្លៃថាក្រុមប្រឹក្សា ឬ តំណាងគណបក្សនយោបាយនៅមូលដ្ឋានមិនបានធ្វើទាល់តែសោះ ឬធ្វើបានតិចតួចចំពោះ តម្រូវការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ តម្រូវការសាងសង់បង្គន់អនាម័យ ធុងចម្រោះទឹកស្អាត និងអណ្ដូងស្នប់ និងមាន១២៩ នាក់ ស្មើនឹង ២៦.១% បានវាយតម្លៃថា ក្រុមប្រឹក្សាឃុំបានធ្វើខ្លះ ចំពោះតម្រូវការទាំងនេះ ហើយមាន ៦២ នាក់ ស្មើនឹង ១២.៥% វាយតម្លៃថាក្រុមប្រឹក្សាឃុំ ឆ្លើយតបបានមធ្យម ឬធ្វើបានពាក់កណ្ដាលនៃតម្រូវ ការរបស់អ្នកភូមិដែលបាន លើកឡើង។ មាន ៣០ នាក់ ស្មើនឹង ៦.១% លើកឡើងថាក្រុមប្រឹក្សា ឃុំធ្វើបានច្រើន ឬឆ្លើយតប បានច្រើនចំពោះតម្រូវការអាទិភាពរបស់ពួកគេ និងមានតែ៤




នាក់ ស្មើនឹង ០.៨% ប៉ុណ្ណោះបាន ផ្ដល់ពិន្ទុវាយតម្លៃថា ក្រុមប្រឹក្សាឃុំ បានឆ្លើយតប ឬធ្វើបានទាំងស្រុងនៅនៃតម្រូវការអាទិភាព ដែល បានលើកឡើងក្នុង សិក្ខាសាលាកន្លងមក។

**អាទិភាពកូដលេខ៨៖ សុំតបណ្តាញអគ្គីសនី សុំម៉ាស៊ីនភ្លើង**

ក្នុងចំណោមអ្នកវាយតម្លៃ ១០៣ នាក់ នៃ១១ឃុំដាច់ស្រយាល មាន៦១ នាក់ ស្មើនឹង៥៩.២% វាយតម្លៃថាក្រុមប្រឹក្សា ឬ តំណាងគណបក្សនយោបាយនៅមូលដ្ឋានមិនបានធ្វើទាល់តែសោះ ឬធ្វើបានតិចតួចចំពោះ តម្រូវការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ តម្រូវការតបណ្តាញ អគ្គីសនី និង សុំម៉ាស៊ីន ភ្លើង និងមាន១២ នាក់ ស្មើនឹង១១.៧%បានវាយតម្លៃថា ក្រុមប្រឹក្សាឃុំបានធ្វើខ្លះ ចំពោះតម្រូវការទាំងនេះ ហើយមាន ២៤ នាក់ ស្មើនឹង ២៣.៣% វាយតម្លៃថាក្រុមប្រឹក្សាឃុំឆ្លើយតបបានមធ្យម ឬធ្វើបានពាក់កណ្តាលនៃ




តម្រូវ ការរបស់អ្នកភូមិដែលបានលើកឡើង។ មាន ៦ នាក់ ស្មើនឹង ៥.៨% លើកឡើងថា ក្រុមប្រឹក្សា ឃុំធ្វើបានច្រើន ឬឆ្លើយតបបានច្រើនចំពោះតម្រូវ ការអាទិភាពរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងមក ។

**អាទិភាពកូដលេខ៩៖ វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ និងពូជសត្វក្របី និងចាក់វ៉ាក់សាំងសត្វ កូនឈើ និងពេទ្យសត្វ ជីកសិកម្ម**

ក្នុងចំណោមអ្នកវាយតម្លៃ ៨៦ នាក់ នៃ៨ឃុំដាច់ស្រយាល មាន២៨ នាក់ ស្មើនឹង៣២.៦% វាយតម្លៃថាក្រុមប្រឹក្សា ឬ តំណាងគណបក្សនយោបាយនៅមូលដ្ឋានមិនបានធ្វើទាល់តែសោះ ឬធ្វើបានតិចតួចចំពោះ តម្រូវ ការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ តម្រូវការវគ្គបណ្តុះបណ្តាល បច្ចេកទេសចិញ្ចឹមសត្វ និងពូជសត្វ និងចាក់ថ្នាំវ៉ាក់សាំងសត្វ កូនឈើ និងពេទ្យសត្វ និងជី កសិកម្ម និង មាន៣០ នាក់ ស្មើនឹង ៣៤.៩% បានវាយតម្លៃថា ក្រុមប្រឹក្សាឃុំបានធ្វើខ្លះ ចំពោះតម្រូវការ ទាំងនេះ ហើយមាន ១៩ នាក់ ស្មើនឹង ២២.១% វាយតម្លៃថាក្រុមប្រឹក្សាឃុំ ឆ្លើយតប បានមធ្យម ឬធ្វើបានពាក់កណ្តាលនៃតម្រូវការរបស់អ្នកភូមិដែលបានលើកឡើង។ មាន ៨ នាក់ ស្មើនឹង ៩.៣% លើកឡើងថាក្រុម

ប្រឹក្សា ឃុំធ្វើបានច្រើន ឬ ឆ្លើយតបបានច្រើនចំពោះ តម្រូវការអាទិភាពរបស់ ពួកគេដែលបានលើក ឡើង និងមានតែ១ នាក់ ស្មើនឹង ១.២% ប៉ុណ្ណោះ បានផ្តល់ ពិន្ទុវាយតម្លៃថា ក្រុមប្រឹក្សាឃុំ បានឆ្លើយតប ឬធ្វើបានទាំងស្រុង នៅនៃតម្រូវការអាទិភាព ដែលបាន លើកឡើងក្នុង សិក្ខាសាលាកន្លងមក។




## អាទិភាពកូដលេខ១០៖ ដោះស្រាយទំនាស់ដីធ្លី ការផ្តល់ដីព្រៃសហគមន៍ និងបង្កើតសហគមន៍

ក្នុងចំណោមអ្នកវាយតម្លៃ ២០៧ នាក់ នៃ២០ឃុំដាច់ស្រយាល មាន១២០ នាក់ ស្មើនឹង៥៨.០% វាយតម្លៃថាក្រុមប្រឹក្សា ឬ តំណាងគណបក្សនយោបាយនៅមូលដ្ឋានមិនបានធ្វើទាល់តែសោះ ឬធ្វើបានតិចតួចចំពោះ តម្រូវ ការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ ការដោះស្រាយទំនាស់ ដីធ្លី ការ ផ្តល់ដីព្រៃសហគមន៍ និងមាន៤៣ នាក់ ស្មើនឹង ២០.៨% បាន វាយតម្លៃថា ក្រុមប្រឹក្សាឃុំបាន ធ្វើខ្លះ ចំពោះ តម្រូវការទាំងនេះ ហើយ មាន ៣៣ នាក់ ស្មើនឹង ១៥.៩% វាយតម្លៃថា ក្រុមប្រឹក្សាឃុំ ឆ្លើយតបបានមធ្យម ឬធ្វើបាន ពាក់កណ្តាលនៃតម្រូវការរបស់អ្នកភូមិដែលបានលើកឡើង។ មាន ៩ នាក់ ស្មើនឹង ៤.៣% លើកឡើងថា ក្រុមប្រឹក្សា ឃុំធ្វើបានច្រើន ឬឆ្លើយតបបានច្រើនចំពោះតម្រូវកា រអាទិភាពរបស់ពួកគេដែលបានលើក



ឡើង និងមានតែ២ នាក់ ស្មើនឹង ១.0% ប៉ុណ្ណោះបានផ្ដល់ ពិន្ទុវាយតម្លៃថាក្រុមប្រឹក្សាឃុំ បានឆ្លើយតប ឬធ្វើបានទាំងស្រុងនៅនៃតម្រូវការអាទិភាព ដែលបាន លើកឡើងក្នុងសិក្ខាសាលាកន្លងមក។

## អាទិភាពកូដលេខ១១៖ ការបង្កើតសហគមន៍ព្រៃឈើ នេសាទ ស្នើសុំការពារព្រៃច្បោះ

ក្នុងចំណោមអ្នកវាយតម្លៃ ៥៦ នាក់ នៃ៦ឃុំជាច់ស្រយាល មាន៩ នាក់ ស្មើនឹង១៦.១% វាយតម្លៃថាក្រុមប្រឹក្សា ឬ តំណាងគណបក្សនយោបាយនៅមូលដ្ឋានមិនបានធ្វើទាល់តែសោះ ឬធ្វើបានតិចតួចចំពោះតម្រូវ ការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ តម្រូវការអោយមានការបង្កើតសហគមន៍ព្រៃឈើ នេសាទជាដើម និងមាន២៨ នាក់ ស្មើនឹង ៥០.0% បានវាយតម្លៃថា ក្រុមប្រឹក្សាឃុំ បានធ្វើខ្លះ ចំពោះតម្រូវការទាំងនេះ ហើយមាន ១៧ នាក់ ស្មើនឹង ៣០.៤% វាយតម្លៃ ថា ក្រុមប្រឹក្សាឃុំ ឆ្លើយ




តបបានមធ្យម ឬធ្វើបានពាក់កណ្ដាលនៃតម្រូវការរបស់អ្នកភូមិដែលបាន លើកឡើង។ មានតែ ១ នាក់ ស្មើនឹង ១.៨%ដូចគ្នាបានវាយតម្លៃថាក្រុមប្រឹក្សាឃុំធ្វើបានច្រើន ឬ ឆ្លើយតបបានច្រើន និងបានឆ្លើយតប ឬធ្វើបានទាំងស្រុងនៅនៃតម្រូវការអាទិភាព ដែលបានលើក ឡើងក្នុងសិក្ខាសាលាកន្លងមក។

## អាទិភាពកូដលេខ១២៖ ពន្លឿនការធ្វើអត្តសញ្ញាណប័ណ្ណ ការធ្វើអត្តសញ្ញាណប័ណ្ណ ការយកលុយធ្វើអត្តសញ្ញាណប័ណ្ណលើសកំណត់

ក្នុងចំណោមអ្នកវាយតម្លៃ ៩១ នាក់ នៃ៨ឃុំជាច់ស្រយាល មាន១១ នាក់ ស្មើនឹង២១.១% វាយតម្លៃថាក្រុមប្រឹក្សា ឬ តំណាងគណបក្សនយោបាយនៅមូលដ្ឋានមិនបានធ្វើទាល់តែសោះ ឬធ្វើបានតិចតួចចំពោះតម្រូវ ការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ តម្រូវការ អោយមានការពន្លឿនការធ្វើអត្តសញ្ញាណប័ណ្ណ និងទប់ស្កាត់ភាពមិនប្រក្រតីក្នុងការធ្វើអត្តសញ្ញាណប័ណ្ណ ដូចជាការយកលុយ




លើសកំណត់ និងមាន ២៧ នាក់ ស្មើនឹង ២៩.៧% បានវាយតម្លៃថា ក្រុមប្រឹក្សាឃុំបាន ធ្វើខ្លះ ចំពោះតម្រូវការទាំងនេះ ហើយមាន ៣៩ នាក់ ស្មើនឹង ៤២.៩% វាយតម្លៃថាក្រុមប្រឹក្សាឃុំឆ្លើយតបបានមធ្យម ឬធ្វើបានពាក់កណ្តាលនៃតម្រូវការរបស់អ្នកភូមិដែលបានលើកឡើង។ មាន ១១ នាក់ ស្មើនឹង ១២.១% លើកឡើងថាក្រុមប្រឹក្សាឃុំធ្វើបានច្រើន ឬឆ្លើយតបបានច្រើនចំពោះ តម្រូវការអាទិភាពរបស់ពួកគេដែលបានលើកឡើង និងមានតែ៣ នាក់ ស្មើនឹង ៣.៣% ប៉ុណ្ណោះ បានផ្តល់ពិន្ទុវាយតម្លៃថាក្រុមប្រឹក្សាឃុំ បានឆ្លើយតប ឬធ្វើបានទាំងស្រុងនៅនៃតម្រូវការអាទិភាព ដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងមក។

**អាទិភាពកូដលេខ១៣៖ បញ្ចុះតម្លៃទំនិញ បញ្ចុះតម្លៃជីកសិកម្ម ប្រេងសាំង ម៉ាស៊ូត និងផ្តល់ពូជស្រូវ**

ក្នុងចំណោមអ្នកវាយតម្លៃ ៥៥ នាក់ នៃ៤ឃុំដាច់ស្រយាល មាន២៣ នាក់ ស្មើនឹង៤១.៨២% វាយតម្លៃថាក្រុមប្រឹក្សា ឬតំណាងគណបក្សនយោបាយនៅមូលដ្ឋានមិនបានធ្វើទាល់តែសោះ ឬធ្វើបានតិចតួចចំពោះតម្រូវ ការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ ការបញ្ចុះតម្លៃទំនិញ ដូចជា ជី



កសិកម្ម ប្រេងសាំង ម៉ាស៊ូតជាដើម និងមាន១៩ នាក់ ស្មើនឹង ៣៤.៥៤% បានវាយតម្លៃថា ក្រុមប្រឹក្សាឃុំបានធ្វើខ្លះ ចំពោះតម្រូវការទាំងនេះ ហើយមានតែ ១ នាក់ ស្មើនឹង ១.៨១% វាយតម្លៃ ថាក្រុមប្រឹក្សាឃុំឆ្លើយតបបានមធ្យម ឬធ្វើបានពាក់កណ្ដាលនៃតម្រូវការរបស់អ្នកភូមិ ដែលបាន លើកឡើង។ រីឯ ១២ នាក់ ស្មើនឹង ១២.១% ផ្សេងទៀតវាយតម្លៃថាក្រុមប្រឹក្សាឃុំធ្វើបានច្រើន ឬឆ្លើយតបបានច្រើនចំពោះតម្រូវការអាទិភាពរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលា កន្លងមក។ ។

## អាទិភាពកូដលេខ១៤៖ ទប់ស្កាត់ក្មេងទំនើង សន្តិសុខសណ្ដាប់ធ្នាប់សន្តិសុខ

ក្នុងចំណោមអ្នកវាយតម្លៃ ៨៣ នាក់ នៃ៧ឃុំដាច់ស្រយាល មាន៥ នាក់ ស្មើនឹង៦.០% វាយតម្លៃថាក្រុមប្រឹក្សា ឬ តំណាងគណបក្សនយោបាយនៅមូលដ្ឋានមិនបានធ្វើទាល់តែសោះ ឬធ្វើបានតិចតួចចំពោះតម្រូវ ការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ ការរក្សាសន្តិសុខសណ្ដាប់ធ្នាប់នៅមូលដ្ឋានដូចជាករណីក្មេងទំនើង ចោរកម្ម និងល្បែងស៊ីសង ។ល។ និងមាន ៣៣ នាក់ ស្មើនឹង ៣៩.៨% បានវាយតម្លៃថា ក្រុមប្រឹក្សាឃុំបាន ធ្វើខ្លះ ចំពោះតម្រូវការទាំងនេះ ហើយមាន ៣២ នាក់




ស្មើនឹង ៣៨.៦% វាយតម្លៃថាក្រុមប្រឹក្សាឃុំ ឆ្លើយតប បានមធ្យម ឬធ្វើបានពាក់កណ្ដាលនៃតម្រូវ ការរបស់អ្នកភូមិដែលបានលើកឡើង។ មាន ១២ នាក់ ស្មើនឹង ១៤.៥% លើកឡើងថាក្រុមប្រឹក្សា ឃុំធ្វើបានច្រើន ឬឆ្លើយតបបានច្រើនចំពោះ តម្រូវការអាទិភាពរបស់ពួកគេដែលបានលើកឡើង និងមានតែ១ នាក់ ស្មើនឹង ១.២% ប៉ុណ្ណោះ បានផ្ដល់ពិន្ទុវាយតម្លៃថាក្រុមប្រឹក្សាឃុំបានឆ្លើយតប ឬធ្វើបានទាំងស្រុងនៅនៃតម្រូវការអាទិភាពដែលបានលើកឡើងខាងលើ។

**អាទិភាពកូដលេខ១៥ ៖ ទប់ស្កាត់ការនេសាទខុសច្បាប់ ការកាត់បន្ថយឡូត៍នេសាទ ស្នើសុំដាក់លប និងកាប់ព្រៃល្បាស់ ការថែរក្សាធនធានធម្មជាតិ ការទប់ស្កាត់ការបំផ្លាញ**

ក្នុងចំណោមអ្នកវាយតម្លៃ ១២៤ នាក់ នៃ១០ឃុំដាច់ស្រយាល មាន៨ នាក់ ស្មើនឹង៦.៥% វាយតម្លៃថា ក្រុមប្រឹក្សា ឬ តំណាងគណបក្សនយោបាយនៅមូលដ្ឋានមិនបានធ្វើទាល់តែសោះ ឬធ្វើបានតិចតួចចំពោះ តម្រូវ ការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ ទប់ស្កាត់ការនេសាទខុសច្បាប់ ការកាត់បន្ថយឡូត៍ នេសាទ ស្នើសុំដាក់លប និងកាប់ព្រៃល្បាស់ ការ ថែរក្សាធនធានធម្មជាតិ ការទប់ ស្កាត់ការ បំផ្លាញព្រៃឈើ និង មាន ៤១ នាក់ ស្មើនឹង ៣៣.១% បានវាយ តម្លៃថា ក្រុមប្រឹក្សាឃុំ បាន ធ្វើខ្លះ ចំពោះតម្រូវ ការទាំងនេះ ហើយមាន ៤០ នាក់ ស្មើនឹង ៣៤.៧% វាយតម្លៃថាក្រុមប្រឹក្សាឃុំ ឆ្លើយតបបានមធ្យម ឬធ្វើ បានពាក់កណ្តាលនៃតម្រូវ ការរបស់អ្នកភូមិដែលបានលើកឡើង។ មាន ១៦ នាក់ ស្មើនឹង ១២.៩% ដូច គ្នាបានវាយតម្លៃថា ក្រុមប្រឹក្សាឃុំធ្វើបានច្រើន ឬឆ្លើយតបបាន ច្រើន និងបានឆ្លើយតប ឬធ្វើបាន ទាំងស្រុងនៅនៃតម្រូវ ការអាទិភាពដែលបានលើ កឡើងខាងលើ។



## អាទិភាពកូដលេខ១៦ (កសិកម្ម និងបង្កើតទីផ្សារលក់ផលិតផលកសិកម្ម)




ក្នុងចំណោមអ្នកវាយតម្លៃ ១១ នាក់ មាន៦ នៃ១ឃុំដាច់ស្រយាល នាក់ ស្មើនឹង៥៤.៤% វាយតម្លៃថាក្រុមប្រឹក្សា ឬ តំណាងគណបក្សនយោបាយនៅមូលដ្ឋាន បានធ្វើខ្លះ ចំពោះតម្រូវការចំពោះតម្រូវការដែលពួកគេ បានលើកឡើង នោះគឺ ទីផ្សារសម្រាប់លក់ផលិតផល កសិកម្ម ហើយមាន ៥ នាក់ ស្មើនឹង ៤៥.៥% វាយតម្លៃថាក្រុមប្រឹក្សាឃុំ ឆ្លើយតបបានមធ្យម ឬធ្វើបានពាក់កណ្តាលនៃតម្រូវការរបស់អ្នកភូមិដែល បានលើកឡើងខាងលើ។

## អាទិភាពកូដលេខ១៧៖ ការបង្រៀន និងវគ្គបណ្តុះបណ្តាលអំពើហឹង្សាក្នុងគ្រួសារ និងច្បាប់ចរាចរ ច្បាប់ភូមិបាល រក្សាប្រពៃណី




ក្នុងចំណោមអ្នកវាយតម្លៃ ១២១ នាក់ នៃ ១០ឃុំដាច់ស្រយាល មាន៤៦ នាក់ ស្មើនឹង ៣៨.០% វាយតម្លៃថា ក្រុមប្រឹក្សា ឬ តំណាងគណបក្សនយោបាយនៅមូលដ្ឋានមិនបានធ្វើទាល់តែសោះ ឬធ្វើបានតិចតួចចំពោះតម្រូវ

ការរបស់ពួកគេដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ ការអប់រំ និងផ្សព្វផ្សាយអំពីច្បាប់ ដូចជា ច្បាប់ភូមិភូមិ ច្បាប់ចរាចរ ការរក្សាប្រពៃណីជនជាតិដើមភាគតិច និង វគ្គបណ្តុះបណ្តាលអំពើ ហឹង្សាក្នុងគ្រួសារ និងមាន ៣២ នាក់ ស្មើនឹង ២៦.៤% បានវាយតម្លៃថា ក្រុមប្រឹក្សាឃុំបានធ្វើខ្លះ ចំពោះតម្រូវការទាំងនេះ ហើយមាន ២៥ នាក់ ស្មើនឹង ២០.៧% វាយតម្លៃថាក្រុមប្រឹក្សាឃុំ ឆ្លើយ តបបានមធ្យម ឬធ្វើបានពាក់កណ្តាលនៃតម្រូវ ការរបស់អ្នកភូមិដែលបានលើកឡើង។ មាន ១០ នាក់ ស្មើនឹង ៨.៣% ដូចគ្នាបានវាយតម្លៃថា ក្រុមប្រឹក្សាឃុំធ្វើបានច្រើន ឬឆ្លើយតបបានច្រើន និងមាន ៨នាក់ ស្មើនឹង ៦.៦% បានវាយតម្លៃថា ក្រុមប្រឹក្សាបានឆ្លើយតប ឬធ្វើបានទាំងស្រុង នៅនៃតម្រូវការអាទិភាពដែលបានលើកឡើងខាងលើ។

### អាទិភាពកូដលេខ១៨៖ សាងសង់ឈាបនដ្ឋាន និងស្ពានីយភ្ញាស់កូនត្រី

ក្នុងចំណោមអ្នកវាយតម្លៃ ១៥ នាក់នៃ១ឃុំដាច់ស្រយាល ទាំងអស់គ្នា បានវាយតម្លៃថាក្រុមប្រឹក្សា ឬតំណាងគណបក្សនយោបាយនៅមូលដ្ឋានធ្វើបាន ឬឆ្លើយតបបានខ្លះៗហើយចំពោះតម្រូវការរបស់ពួកគេ ដែលបាន លើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ ការសាងសង់ឈាបនដ្ឋាន និងស្ពានីយភ្ញាស់កូនត្រី។



### អាទិភាពកូដលេខ១៩៖ សាងសង់ប៉ុស្តិ៍នគរបាលរដ្ឋបាល និងសាលាឃុំ

ក្នុងចំណោមអ្នកវាយតម្លៃ ៦ នាក់ នៃ១ឃុំដាច់ស្រយាលទាំងអស់គ្នា បានវាយតម្លៃថាក្រុមប្រឹក្សា ឬ តំណាងគណបក្ស នយោបាយនៅមូលដ្ឋាន មិនទាន់ធ្វើបានទាល់តែសោះ ឬធ្វើបានតិចតួច ចំពោះតម្រូវការរបស់ពួកគេ ដែលបាន លើកឡើងក្នុងសិក្ខាសាលាកន្លងនោះគឺ តម្រូវការអោយមានការសាងសង់ប៉ុស្តិ៍នគរបាល រដ្ឋបាល និងសាលាឃុំ។




### អាទិភាពកូដលេខ២០៖ ការស្នើសុំជួយសម្រួលបញ្ហាទំនប់វារីអគ្គីសនី

ក្នុងចំណោមអ្នកវាយតម្លៃ ១៥ នាក់ នៃ១ឃុំដាច់ស្រយាល មានស្ទើតែទាំងអស់គឺ ១៤នាក់ ស្មើនឹង ៩៣.៣% បានវាយតម្លៃថាក្រុមប្រឹក្សា ឬ តំណាងគណបក្ស នយោបាយនៅមូលដ្ឋានមិនទាន់ធ្វើបានទាល់តែសោះ ឬធ្វើបានតិចតួច ចំពោះតម្រូវការរបស់ពួកគេ ដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងមកនោះគឺ ការស្នើសុំអោយជួយសម្រួលបញ្ហាទំនប់វារីអគ្គីសនី ដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងមានត្រឹមតែ ៦.៧% ប៉ុណ្ណោះបានវាយតម្លៃថាក្រុមប្រឹក្សាឃុំឆ្លើយតបបាន ឬធ្វើបានខ្លះៗ។



## អាទិភាពកូដលេខ២១៖ សុំអាហារូបករណ៍សម្រាប់សិស្សក្រីក្រ និងរកការងារ




ក្នុងចំណោមអ្នកវាយតម្លៃ ១០ នាក់ នៃ១ឃុំដាច់ស្រយាល ទាំងអស់គ្នាវាយតម្លៃថាក្រុមប្រឹក្សា ឬតំណាងគណបក្សនយោបាយនៅមូលដ្ឋាន មិនទាន់ធ្វើបាន ទាល់តែសោះ ឬធ្វើបានតិចតួចចំពោះតម្រូវការរបស់ពួកគេ ដែលបានលើកឡើងក្នុងសិក្ខាសាលាកន្លងមកនោះគឺ សុំអាហារូបករណ៍សម្រាប់សិស្សដែល មានជីវភាពក្រីក្រ និងរកការងារ។

ឧបសម្ព័ន្ធ៖

**ទម្រង់វាយតម្លៃអំពីការអនុវត្តន៍ ការបំពេញ និងការឆ្លើយតបរបស់ក្រុមប្រឹក្សាឃុំ តំណាង គណបក្សនយោបាយក្នុងឃុំចំពោះតម្រូវអាទិភាពទាំង៥**

| | | | |
|---|---|---|---|
| ឈ្មោះអ្នកវាយតម្លៃ: | | ហត្ថលេខាអ្នកវាយតម្លៃ: | |
| ទីកន្លែងសម្ភាសន៍/ ភូមិ៖ | | ឃុំ/កូដឃុំ៖ | ....................../.................... |
| ស្រុក៖ | | ខេត្ត៖ | |
| ថ្ងៃ ខែ ឆ្នាំសម្ភាសន៍៖ | ........../........../........... | ថ្ងៃ ខែ ឆ្នាំផ្ញើរសារ៖ | ........../........../........... |

*ខាងក្រោមនេះគឺជាសំណួរវាយតម្លៃការអនុវត្តន៍ ការបំពេញ ការឆ្លើយតបរបស់ក្រុមប្រឹក្សាឃុំ តំណាង គណបក្សនយោបាយលើតម្រូវការអាទិភាពទាំង៥ខាងក្រោម។ លោកអ្នកត្រូវបានលើក ទឹកចិត្ត(លើក លែងតែក្រុមប្រឹក្សាឃុំ)អោយចូលរួមផ្តល់ចម្លើយវាយតម្លៃ នៅលើតារាងពិន្ទុ ដោយគូសរង្វង់ ឬសញ្ញា( ✓)ក្នុងប្រអប់ □ តាមការយល់ឃើញរៀងៗខ្លួន៖*

## ខាងក្រោមគឺជាចំណុចដែលត្រូវវាយតម្លៃ៖

តើការបំពេញ ឬការឆ្លើយតបរបស់ក្រុមប្រឹក្សាឃុំ តំណាងគណបក្សនយោបាយចំពោះតម្រូវការ អាទិភាពទាំង៥ក្នុងឃុំរបស់អ្នកខាងក្រោមបានកម្រិតណាដែរ?

| | | | | |
|---|---|---|---|---|
| ១. ការសាងសង់ផ្លូវស្ពាននិងលូ (កូដ=២) | | | | |
| □ ១=បានធ្វើតិចតួច ឬ មិនបានធ្វើសោះ | □ ២=បានធ្វើខ្លះ | □ ៣=បានធ្វើពាក់កណ្តាល | □ ៤=បានធ្វើច្រើន | □ ៥=បានធ្វើទាំងស្រុង |
| ២. ការសាងសង់ទំនប់ ស្រះទឹក និងទ្វារទឹក (កូដ=៧) | | | | |
| □ ១=បានធ្វើតិចតួច ឬ មិនបានធ្វើសោះ | □ ២=បានធ្វើខ្លះ | □ ៣=បានធ្វើពាក់កណ្តាល | □ ៤=បានធ្វើច្រើន | □ ៥=បានធ្វើទាំងស្រុង |
| ៣. ការសាងសង់បង្គន់អនាម័យនិងប៉ុស្តិ៍សុខភាព (កូដ=៨) | | | | |
| □ ១=បានធ្វើតិចតួច ឬ មិនបានធ្វើសោះ | □ ២=បានធ្វើខ្លះ | □ ៣=បានធ្វើពាក់កណ្តាល | □ ៤=បានធ្វើច្រើន | □ ៥=បានធ្វើទាំងស្រុង |

| ៤. ការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម (កូដ=១៣) | | | | |
|---|---|---|---|---|
| ☐<br>១=បានធ្វើតិចតួច ឬ មិនបានធ្វើសោះ | ☐<br>២=បានធ្វើខ្លះ | ☐<br>៣=បានធ្វើពាក់កណ្តាល | ☐<br>៤=បានធ្វើច្រើន | ☐<br>៥=បានធ្វើទាំងស្រុង |
| **៥. សន្តិសុខសណ្តាប់ធ្នាប់ (កូដ=១៨)** | | | | |
| ☐<br>១=បានធ្វើតិចតួច ឬ មិនបានធ្វើសោះ | ☐<br>២=បានធ្វើខ្លះ | ☐<br>៣=បានធ្វើពាក់កណ្តាល | ☐<br>៤=បានធ្វើច្រើន | ☐<br>៥=បានធ្វើទាំងស្រុង |